**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ០៥១.......សហវ.......

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងាររៀបចំមគ្គុទេសក៍គ្រប់គ្រងហិរញ្ញវត្ថុ សម្រាប់ប្រើប្រាស់ផ្ទៃក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៨៤៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤២៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងដាក់ឱ្យអនុវត្តអង្គភាពថវិកា
- បានឃើញប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងាររៀបចំមគ្គុទេសក៍គ្រប់គ្រងហិរញ្ញវត្ថុ សម្រាប់ប្រើប្រាស់ផ្ទៃក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានសមាសភាព ដូចខាងក្រោម÷

| | | |
|---|---|---|
| ១. ឯកឧត្តម **មាស សុខសេនសាន** | អគ្គលេខាធិការ កសហវ. និងជាអគ្គលេខាធិការរង នៃ អ.គ.ហ. | ប្រធាន |
| ២. លោក **យ៉េត ទីណែល** | អគ្គលេខាធិការរង កសហវ. និងជា អគ្គលេខាធិការរង នៃ អ.គ.ហ. | អនុប្រធានប្រចាំការ |
| ៣. លោក **គុយ សាទុច** | អគ្គលេខាធិការរង កសហវ. | អនុប្រធាន |
| ៤. លោក **ងិត ចន្ថា** | ប្រធាននាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ | សមាជិក |
| ៥. លោក **អ៊ុត សុផា** | អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ | សមាជិក |
| ៦. លោកស្រី **មាន់ ស៊ីម្ញូរ៉ែន** | អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ | សមាជិក |
| ៧. លោកស្រី **សូច សូរិយា** | អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ | សមាជិក |
| ៨. លោកស្រី **ឆាន់ ទីរ៉ៃយ៉ា** | ប្រធានអង្គភាពលទ្ធកម្ម | សមាជិក |
| ៩. លោក **សាយ អ៊ាន** | ប្រធានការិយាល័យផែនការថវិកា | សមាជិក |
| ១០. លោក **គ្រឿង ប្រណិត** | ប្រធានការិយាល័យគណនេយ្យ | សមាជិក |
| ១១. លោក **ឌុំ ម៉ុងហេង** | អនុប្រធានការិយាល័យផែនការថវិកា | សមាជិក |
| ១២. លោក **ឈាង ដាវី** | អនុប្រធានការិយាល័យផែនការថវិកា | សមាជិក |
| ១៣. លោក **ស ចាន់ទីរៈ** | អនុប្រធានការិយាល័យគណនេយ្យ | សមាជិក |
| ១៤. លោក **អ៊ុំ យុទ្ធី** | ប្រធានផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ នៃ អ.គ.ហ. | សមាជិក |
| ១៥. លោក **ឡៀង សុខតីរម្យ** | មន្ត្រីជំនាញជាន់ខ្ពស់ នៃ អ.គ.ហ. | សមាជិក |
| ១៦. លោក **អ៊ុច សោភ័ណ** | មន្ត្រីជំនាញជាន់ខ្ពស់ នៃ អ.គ.ហ. | សមាជិក |
| ១៧. លោក **យន ម៉ាលីមនេង** | មន្ត្រីជំនាញជាន់ខ្ពស់ នៃ អ.គ.ហ. | សមាជិក |
| ១៨. លោក **លី ទ៉ុង** | មន្ត្រីជំនាញជាន់ខ្ពស់ នៃ អ.គ.ហ. | សមាជិក |
| ១៩. លោកស្រី **សុគន្ធ ចរិយា** | មន្ត្រីថវិកា នៃ អ.គ.ហ. | សមាជិក |
| ២០. លោកស្រី **ហួត សំណាង** | មន្ត្រីការិយាល័យផែនការថវិកា | សមាជិក |
| ២១. លោកស្រី **ខេមរិន្ទ រចនា** | មន្ត្រីការិយាល័យផែនការថវិកា | សមាជិក |
| ២២. លោក **ហាក់ រដ្ឋា** | មន្ត្រីការិយាល័យផែនការថវិកា | សមាជិក |
| ២៣. លោកស្រី **ស៊ុម ច័ន្ទសូរិយា** | មន្ត្រីការិយាល័យផែនការថវិកា | សមាជិក |
| ២៤. លោក **ឈឹម ច័ន្ទដារ៉ូ** | មន្ត្រីការិយាល័យផែនការថវិកា | សមាជិក |
| ២៥. លោក **ម៉ុន ហៃ** | មន្ត្រីការិយាល័យផែនការថវិកា | សមាជិក |
| ២៦. លោក **ជ័យ រ៉ានុត** | មន្ត្រីការិយាល័យផែនការថវិកា | សមាជិក |
| ២៧. លោក **ផល សុលី** | មន្ត្រីជាប់កិច្ចសន្យា នៃការិយាល័យផែនការថវិកា | សមាជិក |
| ២៨. លោក **ហ៊ុម សុវណ្ណដារ៉ា** | មន្ត្រីជាប់កិច្ចសន្យា នៃការិយាល័យផែនការថវិកា | សមាជិក។ |

**ប្រការ២.-**

ក្រុមការងាររៀបចំមគ្គុទេសក៍គ្រប់គ្រងហិរញ្ញវត្ថុ សម្រាប់ប្រើប្រាស់ផ្ទៃក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចដូចតទៅ÷

- រៀបចំចងក្រងសេចក្តីព្រាង "មគ្គុទេសក៍គ្រប់គ្រងហិរញ្ញវត្ថុ" សម្រាប់ប្រើប្រាស់ផ្ទៃក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយប្រមូលផ្តុំនូវការណែនាំអនុវត្តវិធាននិងនីតិវិធីហិរញ្ញវត្ថុជាធរមាន ក្នុងការរៀបចំ ការអនុវត្ត ការតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តថវិកា ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងសវនកម្មនិងអធិការកិច្ច ក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយអង្គភាពជំនាញ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើសេចក្តីព្រាងមគ្គុទេសក៍គ្រប់គ្រងហិរញ្ញវត្ថុ សម្រាប់ប្រើប្រាស់ផ្ទៃក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីជានាសង្គតិភាពគតិយុត្តជាមួយបទប្បញ្ញត្តិជាធរមាន
- បំពេញភារកិច្ចផ្សេងៗទៀត តាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៣.-**

អនុប្រធានប្រចាំការ អនុប្រធាន និងសមាជិក ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារ។ ប្រធានក្រុមការងារ អាចប្រគល់សិទ្ធិជូនអនុប្រធានប្រចាំការ ឬអនុប្រធាន ដឹកនាំកិច្ចប្រជុំជំនួស និងអាចអញ្ជើញថ្នាក់ដឹកនាំនៃអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យចូលរួមប្រជុំតាមការចាំបាច់។

**ប្រការ៤.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៦

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ